# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ១៤៩ .......................ក.ប/ប្រ.ក

## ប្រកាស
## ស្តីពី
## ការបង្កើតវិទ្យាស្ថានអាស៊ី កម្ពុជា

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ០៧២/១១ ក.ប/ប្រ.ក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាមសំណើរបស់លោកនាយកវិទ្យាស្ថានអាស៊ី កម្ពុជា ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១

## សម្រេច

**ប្រការ១:** ត្រូវបានអនុញ្ញាតឲ្យបង្កើតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយដែលមានឈ្មោះថា "វិទ្យាស្ថានអាស៊ី កម្ពុជា" សរសេរកាត់ថា "វ.អ.ក" ជាភាសាអង់គ្លេស "Asian Institute of Cambodia" សរសេរកាត់ថា "A.I.C" ។ វិទ្យាស្ថានអាស៊ី កម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅផ្លូវលេខ ៧៣ ភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ។

**ប្រការ ២:** វិទ្យាស្ថានអាស៊ី កម្ពុជា បណ្តុះបណ្តាលជំនាញដូចខាងក្រោម ៖

ក. កម្រិតវិញ្ញាបនបត្រ សិក្សារយៈពេលក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ

ខ. កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ៦៦

រួមមានជំនាញ ៖ អក្សរសាស្ត្រអង់គ្លេស ព័ត៌មានវិទ្យា គ្រប់គ្រងពាណិជ្ជកម្ម កសិកម្ម នីតិសាស្ត្រ វិស្វកម្មសំណង់ និងវិស្វកម្មអគ្គិសនី និងអេឡិចត្រូនិច ។

ទៅអនាគត វិទ្យាស្ថានអាស៊ី កម្ពុជា អាចបង្កើតសាខា ឬដំឡើងកម្រិតបណ្តុះបណ្តាល និងជំនាញផ្សេងៗទៀតតាមការរីកចម្រើនរបស់វិទ្យាស្ថានដោយសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៣:** លក្ខខណ្ឌទទួលសិស្ស និស្សិតឲ្យចូលរៀន ៖

- កម្រិតវិញ្ញាបនបត្រ សម្រាប់បេក្ខជនជាសិក្ខាកាម សិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ ។
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ( ជាប់ឬធ្លាក់ ) ឬមានកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬមានសញ្ញាបត្រដែលមានតម្លៃស្មើ។

**ប្រការ ៤:** វិទ្យាស្ថានអាស៊ី កម្ពុជា ដឹកនាំដោយនាយក ០១ រូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ ៥:** នាយកវិទ្យាស្ថានអាស៊ី កម្ពុជាមានភារកិច្ច ៖

- ជ្រើសរើសសិស្ស និស្សិត សិក្ខាកាមឲ្យចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបម្រើការងារ
- គ្រប់គ្រងឲ្យបានល្អនូវការបង្រៀន ការអនុវត្តន៍ជាក់ស្តែង ការសិក្សា ការប្រឡង ការប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រ
- គោរព និងអនុវត្តតាមសារាចរ និងសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើរបាយការណ៍រាល់សកម្មភាពបណ្តុះបណ្តាលជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ( នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ) ប្រចាំវគ្គនីមួយៗ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំឲ្យបានទៀងទាត់ ។

**ប្រការ ៦:** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល និងមានសិទ្ធិបិទ ក្នុងករណីវិទ្យាស្ថានអាស៊ី កម្ពុជាអនុវត្តខុសពីច្បាប់រដ្ឋ ។

**ប្រការ ៧:** សិស្ស និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ ហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមជំនាញដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្តល់ឲ្យដោយវិទ្យាស្ថានអាស៊ី កម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ។

**ប្រការ ៨:** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងនាយកវិទ្យាស្ថានអាស៊ី កម្ពុជា មានភារកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ ។

**ប្រការ ៩:** ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន**

- សាលានេត្តគ្រប់ដេះ
  "ដើម្បីជ្រាបជាព័ត៌មាន"
- វិទ្យាស្ថានអាស៊ី កម្ពុជា "ដើម្បីអនុវត្ត"
- ដូចប្រការ ៨
- ឯកសារ ន.គ.ក.អ.ប.វ
- កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥